# រដ្ឋាភិបាលគួរទទួលយកមតិរិះគន់ដើម្បីជំរុញឱ្យស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាប្រសើរឡើង



*លោក រស់ សារ៉ាត់ អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋាននៅ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ (រូបថត៖ ផ្ដល់ដោយលោក រស់ សារ៉ាត់)*

By [នឿន ស្រីណែត (Noeurn Sreyneth)]

August 8, 2024

ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាត្រូវបានស្ថាប័នអន្តរជាតិមួយចំនួនដូចជាក្រសួងការបរទេសសហរដ្ឋអាមេរិក និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ជាដើម រកឃើញថានៅតែមានភាពអាក្រក់ ដោយសារមានការរឹតត្បិតធ្ងន់ធ្ងរលើសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សេរីភាពតាមអ៊ីនធឺណិ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងការបរិហាកេរ្តិ៍ ដើម្បីរឹតត្បិតលើការបញ្ចេញមតិរបស់ពលរដ្ឋ។

ខាងក្រោមនេះជាកិច្ចសម្ភាសន៍រវាងលោក រស់ សារ៉ាត់ អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋាននៅ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងកញ្ញា នឿន ស្រីណែត សិក្ខាកាមនៅញូវរូមខេមបូឌា (NewsroomCambodai)៖

Q: នាងខ្ញុំសូមជម្រាបសួរ លោក រស់ សារ៉ាត់!

A: បាទជម្រាបសួរ!

Q: ជាដំបូងនាងខ្ញុំសូមសួរថា តើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាមានស្ថានភាពបែបណាវាំង ៥ឆ្នាំមុន និងពេលបច្ចុប្បន្ន?

A: បាទ! មែនទែនទៅអាចនឹងពិបាកក្នុងការរកទិន្នន័យមកប្រៀបធៀបថាតើ៥ឆ្នាំមុន និងពេលបច្ចុប្បន្ននេះតើមានភាពខុសគ្នាយ៉ាងណា ប៉ុន្តែបើយើងមើលទៅតាមទិដ្ឋភាពជាក់ស្តែង យើងឃើញថាការរឹតត្បិត ការរំលោភសិទ្ធិ រំលោកបំពានទៅលើអ្នកដែលគាត់ធ្វើការសិទ្ធិមនុស្សហ្នឹងនៅតែកើតមានអ្នកដែលមានសំឡេងជំទាស់ សំឡេងរិះគន់ហ្នឹង គឺតែងតែរងការរឹតត្បិតជាហូរហែ អីចឹងនៅតែបន្តកើតឡើង ពីមួយឆ្នាំទៅមួយឆ្នាំ សម្រាប់ខ្ញុំផ្ទាល់ដូចជាមើលមិនឃើញការវិវត្តអីល្អប្រសើរច្រើនទេរយៈពេល៥ឆ្នាំកន្លងមកនេះ។

មួយទៀត ទាក់ទងជាមួយនឹងការវិវត្តនៃច្បាប់ដែលមានលក្ខណៈរឹតត្បិតទៅលើ ជាសេរីភាពជាមូលដ្ឋាន អីចឹងយើងឃើញមួយរយៈប៉ុន្មានឆ្នាំចុងក្រោយនេះ មានការអនុវត្ត មានការបង្កើតច្បាប់ បង្កើតអនុក្រឹត្យអីជាហូរហែដែលទទួលរងនូវការរិះគន់ពីមតិជាតិ មតិអន្តរជាតិ ពីអង្គការសង្គមស៊ីវិលអីជាដើម។ ឧទាហរណ៍ដូចជា អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលអាចនឹងត្រូវប្រើប្រាស់ដើម្បីរឹតត្បិតទៅលើសេរីភាព បញ្ចេញមតិជាដើម។ ប៉ុន្តែជាផលល្អដែលអនុក្រឹត្យនេះត្រូវបានផ្អាកការអនុវត្តជាបណ្តោះអាសន្នសិន ហើយក្នុងអំឡុងពេលកូវីដ យើងក៏ឃើញមានច្បាប់ស្តីពីវិធានការការទប់ស្កាត់ការឆ្លងជំងឺរីករាលដាលទាក់ទងនឹងកូវីដ និងជំងឺកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយយើងឃើញថាកន្លងមកច្បាប់នេះត្រូវបានប្រើប្រាស់ប្រឆាំងទៅនឹងអ្នកដែលគាត់ប្រើប្រាស់សេរីភាពបញ្ចេញមតិរបស់គាត់ទៅលើភាពជួបប្រជុំជាដើម។

ក្រៅពីនេះយើងក៏ឃើញមានច្បាប់ផ្សេងៗដែលមានលក្ខណៈរឹតត្បិត ដូចជា អនុក្រឹត្យស្តីពីការគ្រប់គ្រងនៃការប្រើប្រាស់ដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមជាដើម តាមការវិភាគរបស់អ្នកជំនាញ គេឃើញថាបទដ្ឋាន ឬក៏ការវិវត្តនៃអនុក្រឹត្យនៃច្បាប់ទាំងអស់ហ្នឹងគឺមានលក្ខណៈរឹតត្បិតទៅលើការប្រើប្រាស់សេរីភាពជាមូលដ្ឋានរបស់អ្នកដែលមានសំឡេងបែបរិះគន់អីជាដើម។

ហើយយើងមើលមួយទៀតទាក់ទងជាមួយនឹង សួរថាតើមានការវិវត្តន៍បែបណារយៈពេល ៥ឆ្នាំមកហ្នឹង យើងឃើញថាអ្នកការពារសិទ្ធិមនុស្ស អ្នកដែលគាត់ហ៊ានបញ្ចេញសំឡេងប្រឆាំង គឺគាត់តែងតែរងនូវការទទួលបាននូវការប្រើប្រាស់នូវយន្តការច្បាប់ ដើម្បីធ្វើការដាក់ទោសទណ្ឌទៅលើគាត់ ហើយក៏អ្នកការពារសិទ្ធិមនុស្ស អ្នកហ៊ានអនុវត្តនូវសេរីភាពបញ្ចេញមតិ អ្នកខ្លះក៏រងការវាយដំ រងការចាប់ចង។

មួយទៀត បើយើងមើលរបាយការណ៍ដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចងក្រងឡើងជាមួយសមាគមអាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព យើងបានចងក្រងរយៈពេល៥ឆ្នាំចុងក្រោយ ឆ្នាំ២០១៩ យើងឃើញថាការរឹតត្បិតទៅលើសេរីភាពមូលដ្ឋានមានកម្រិតខ្ពស់ ដល់ឆ្នាំ២០២០ ២០២១ រៀងថយចុះបន្តិច ដោយសារតែយើងដឹងហើយថាសម័យកាលនោះ គឺជាសម័យកាលដែលមានការកើតឡើងករណីកូវីដ១៩ច្រើន ហើយនៅឆ្នាំ២០២២ ២០២៣ ការរំលោភបំពាន ការរឹតត្បិតទៅលើសេរីភាពមូលដ្ឋានបានបន្តការកើនឡើងជាថ្មីម្តងទៀត។

យើងឃើញថាទាំងអស់នឹងនៅតែ ការរំលោភបំពាន ការរឹតត្បិតទៅលើអ្នកដែលហ៊ានអនុវត្ត។ និយាយជារួមគឺស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅតែបន្តរងការរឹតត្បិតបន្តទៀត ហើយក្នុងនោះយើងឃើញដូចជាឆ្នាំ២០២៣កន្លងទៅមានការបិទសារព័ត៌មានឯករាជ្យ ហើយថ្មីៗនេះមានការចាប់ចងសកម្មជនអ្នកដែលហ៊ានបញ្ចេញមតិជាសាធារណៈតាមបណ្តាញសង្គម។

បើយើងមើលទៅលើសន្ទស្សន៍ទាក់ទងជាមួយនឹងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២៤ យើងមានចំណាត់ថ្នាក់លេខ១៥១ ក្នុងចំណោម១៥០ នេះគឺជាចំណាត់ថ្នាក់ផ្តល់ដោយអង្គការអ្នកសារព័ត៌មានគ្មានព្រំដែនដែលគាត់ចងក្រងរបាយការណ៍នេះឡើង ហើយយើងមើលឆ្នាំ២០២០ សេរីភាពសារព័ត៌មានរបស់យើងនៅចំណាត់ថ្នាក់លេខ១៤៤ ក្នុង១៨០ អីចឹងឡូវឡើងដល់១៥១ មានន័យថាចំណាត់ថ្នាក់របស់យើងធ្លាក់ដល់ទៅ ៧លេខនៅក្នុងចំណោម១៨០ប្រទេស ដែនដីដែលខាងអ្នកសារព័ត៌មានគ្មានព្រំដែនហ្នឹងគាត់បានចងក្រងឡើង។ មួយទៀតបើយើងមើលទាក់ទងជាមួយនឹងសន្ទស្សន៍ពាក់ព័ន្ធជាមួយនឹងអំពើពុករលួយឆ្នាំ២០២៣ យើងជាប់ចំណាត់ថ្នាក់លេខ១៥៨ ក្នុង១៨០ ជាចំណាត់ថ្នាក់មួយនៅមិនទាន់ល្អប្រសើរនៅឡើយ។

Q: យោងតាមរបាយការណ៍ស្តីពីសិទ្ធិមនុស្សនៅក្នុងឆ្នាំ២០២៣ ដែលចេញដោយស្ថានទូតសហរដ្ឋអាមេរិកកាលពីខែមេសា ឆ្នាំ២០២៤ បានលើកឡើងអំពីចំណុចដែលអាជ្ញាធរតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់ មុននឹងធ្វើការចោទប្រកាន់  ព្រមទាំងមានការចាប់ខ្លួនតាមតែអំពើចិត្តជាដើម។ តើលោកយល់យ៉ាងណាចំពោះរបាយការណ៍នេះ?

A: ខ្ញុំគិតថាវាជាការរកឃើញត្រឹមត្រូវ ព្រោះកន្លងមកខាងពន្ធនាគារ ខាងក្រសួងមហាផ្ទៃ ក៏គាត់ទទួលស្គាល់ដែរ ទាក់ទងជាមួយនឹងការចង្អៀតណែននៅក្នុងពន្ធនាគារ ហើយខាងក្រសួងយុត្តិធម៌ គាត់ក៏មានយុទ្ធនាការ ដើម្បីរំដោះរឿងក្តីដែលជាប់គាំងឱ្យបានលឿនតាមដែលអាចធ្វើទៅបានដើម្បីបន្ធូរបន្ថយស្ថានភាពក្នុងពន្ធនាគារ ឬក៏ករណីដែលមានការជាប់គាំងទាំងអស់ហ្នឹង។ ចំណាត់ការនេះខ្ញុំយល់ថា សូម្បីតែក្រសួង សូម្បីតែរដ្ឋាភិបាល ក៏គាត់ទទួលស្គាល់ថាមានការឃុំខ្លួនហួសរយៈពេលជា

ដើម  អីចឹងដើម្បីដោះស្រាយបញ្ហានេះបានខ្ញុំយល់ថារដ្ឋាភិបាលគួរតែធ្វើម៉េចពិនិត្យមើលទៅលើករណីទាំងអស់ហ្នឹងដើម្បីកុំឱ្យមានការឃុំខ្លួនហួសរយៈពេលកំណត់។

មួយទៀតជាគោលការណ៍រដ្ឋាភិបាលគួរតែពិចារណា ទាក់ទងជាមួយនឹងគោលការណ៍សិទ្ធិទទួលបានការកាត់ក្តីដោយគ្មានការពន្យាពេលស្របទៅតាមក្រមនិតិវិធីព្រហ្មទណ្ឌដែលកំណត់រយៈពេល ហើយមួយទៀតទាក់ទងជាមួយនឹងការឃុំខ្លួន ទាក់ទងជាមួយនឹងគោលការណ៍ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិសន្មតជាមុនថាគ្មានទោស អីចឹងដរាបណាពួកគាត់ជាជនសង្ស័យ ជាជនជាប់ចោទជាដើម គួរតែផ្តល់អត្ថប្រយោជន៍សម្រាប់គាត់មុនពេលដែលឃុំខ្លួន។ យើងគួរតែពិនិត្យមើលទៅក្រមនីតិវិធីដែលចែងពីគោលការណ៍ជនជាប់ចោទត្រូវតែមាន  សិទ្ធិសេរីភាពទាក់ទងជាមួយនឹងតាមមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យើងមើលមួយទៀតទាក់ទងជាមួយនឹង សន្ទស្សន៍នីតិរដ្ឋដែលអង្គការគម្រោងយុត្តិធម៌ពិភពលោកគាត់បានធ្វើឡើងដែលចេញនាពេលកន្លងទៅ ដូចជានៅឆ្នាំ២០២២ យើងអាចមើលតួលេខ ២ឆ្នាំចុងក្រោយ នៅឆ្នាំ២០២២ ប្រទេសកម្ពុជាយើងជាប់ចំណាត់ថ្នាក់លេខ១៣៩ ក្នុងចំណោម១៤០ប្រទេសដែលជាចំណាត់ថ្នាក់ដ៏អាក្រក់បំផុត ទាក់ទងជាមួយនឹងប្រព័ន្ធយុត្តិធម៌របស់កម្ពុជារបស់យើង ហើយក្នុងឆ្នាំ២០២៣ គឺកម្ពុជាជាប់លេខរៀងទី១៤០ ក្នុងចំនួន១៤១ប្រទេសដែនដីដែលខាងគម្រោងយុត្តិធម៌ពិភពលោកគាត់បានធ្វើការសិក្សាស្រាវជ្រាវ។ អីចឹងបើនិយាយឱ្យល្អស្តាប់គឺយើងជាប់លេខ២ ប៉ុន្តែលេខ២ពីក្រោមទៅ។

Q: កាលពីដើមខែ កក្កដានេះឃើញថាមានការចាប់ខ្លួនសកម្មជនបរិស្ថានមាតាធម្មជាតិទាំង ៥រូបដោយកំហែល តើការធ្វើបែបនេះលោកយល់ថាយ៉ាងណាដែរ?

A: សម្រាប់ខ្ញុំយល់ថា ពួកគាត់គឺជាពលរដ្ឋសកម្ម ជាយុវជនសកម្មដែលគួរតែត្រូវទទួលបានការលើកទឹកចិត្ត ការគាំទ្រចំពោះសកម្មភាពដែលគាតើបានធ្វើកន្លងមក ហើយសកម្មភាពដែលគាត់ធ្វើកន្លងមកហ្នឹងគឺជាសកម្មភាពដើម្បីការពារនូវសម្បត្តិធម្មជាតិរបស់ប្រទេសកម្ពុជាយើង។ មានប្រជាពលរដ្ឋមិនច្រើនទេដែលហ៊ានធ្វើសកម្មភាពដូចគាត់។ មួយទៀត ការរារាំងទៅដល់សកម្មភាពរបស់ពួកគាត់គួរតែត្រូវបានហាមឃាត់ បើយើងមើលកន្លងមកពួកគាត់គឺជាអ្នកលះបង់ជាងប្រជាពលរដ្ឋទូទៅ គាត់សុខចិត្តធ្វើសកម្មភាពដែលអ្នកដទៃមិនហ៊ានធ្វើ។ កន្លងមកពួកគាត់ទទួលបានការទទួលស្គាល់ជាអន្តរជាតិ ទទួលបានការផ្តល់ជាពានរង្វាន់សម្រាប់សកម្មភាពរបស់គាត់ ប៉ុន្តែអាជ្ញាធរខ្មែរបែរជាចាប់ខ្លួនរបស់ពួកគាត់ បែរជារាំងនូវសកម្មភាពដែលគួរតែទទួលបានការសាទរពីមជ្ឈដ្ឋានទូទៅ។ រាល់ការបញ្ចេញមតិ រាល់ការប្រើប្រាស់សេរីភាពជាមូលដ្ឋាន សេរីភាពជួបជុំ សេរីភាពបង្កើតសមាគមអីជាដើម

ហ្នឹង គួរតែត្រូវបានបើកទូលាយជាជាងការហាមឃាត់ អ៊ីចឹងមិនមែនសម្រាប់តែក្រុមពួកគាត់ទេដែលជាសកម្មជនបរិស្ថានទេ សម្រាប់ប្រជាពលរដ្ឋទូទៅ សម្រាប់សង្គមស៊ីវិល។

Q: តើនឹងមានបញ្ហាប្រឈមអ្វីខ្លះ ប្រសិនបើពលរដ្ឋមិនមានការយល់ពីសិទ្ធិរបស់ខ្លួន?

A: ជាទូទៅនៅពេលដែលបុគ្គលណាម្នាក់ គាត់មិនបានដឹងអ្វីមួយអ៊ីចឹង បើគាត់មិនបាននូវធាតុចូលអ្វីមួយ អ៊ីចឹងធាតុចេញរបស់គាត់ហ្នឹងក៏មិនមានច្រើនដែរ។ នៅពេលដែលប្រជាពលរដ្ឋគាត់ខ្វះចំណេះដឹងអំពីសិទ្ធិរបស់គាត់ អ៊ីចឹងគាត់នឹងបាត់បង់ឱកាស ឬក៏ខ្វះឱកាសនៅក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិរបស់គាត់ហ្នឹង បើសិនជាគាត់មិនដឹងពីសិទ្ធិរបស់គាត់។ ឧទាហរណ៍ដូចជាសិទ្ធិក្នុងការចូលរួមសកម្មភាពនយោបាយអីជាដើម។ បើសិនជាគាត់មិនដឹងថាគាត់មានសិទ្ធិក្នុងការទៅបោះឆ្នោតទេ អ៊ីចឹងគាត់នឹងបាត់បង់ឱកាសក្នុងការចូលរួមជ្រើសរើសអ្នកតំណាងរបស់គាត់មួយ ជារួមនៅពេលដែលគាត់មិនដឹងអ្វីមួយ គាត់នឹងបាត់បង់ឱកាសក្នុងការធ្វើអ្វីមួយ។នៅក្នុងសង្គមប្រជាធិបតេយ្យគេលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមឱ្យបានសកម្មក្នុងសកម្មភាពនយោបាយ។ សកម្មភាពនយោបាយមិនមានន័យថាយើងទៅធ្វើនយោបាយដើម្បីឱ្យគេបោះឆ្នោតឱ្យទេ ប៉ុន្តែបានន័យថាយើងចូលរួមក្នុងការតាមដាន យើងចូលរួមក្នុងការជ្រើសរើសអ្នកតំណាងរបស់យើងឱ្យស្របទៅតាមឆន្ទៈរបស់យើង អ៊ីចឹងបើសិនជាយើងបាត់បង់ព័ត៌មាន យើងមិនដឹងពីសិទ្ធិរបស់យើង អ៊ីចឹងយើងប្រាកដណាស់ថាយើងបាត់បង់ឱកាសនៅក្នុងការចូលរួមអ្វីម៉្យាង។ ខ្ញុំលើកទឹកចិត្តឱ្យប្រជាពលរដ្ឋគ្រប់រូប ជាពិសេសគឺយុវជនជំនាន់ថ្មីនេះ ធ្វើម៉េចឱ្យស្វះស្វែងយល់ដឹងអំពីសិទ្ធិ កាតព្វកិច្ច ករណីយកិច្ចរបស់ខ្លួនឱ្យក្លាយជាពលរដ្ឋសកម្មក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិយើង។

Q: តើរដ្ឋាភិបាល ជាពិសេសភាគីពាក់ព័ន្ធគួរធ្វើបែបណាដើម្បីឱ្យស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាមានភាពប្រសើរឡើង?

A: ទាក់ទងជាមួយនឹងធ្វើយ៉ាងម៉េចទើបឱ្យស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា មានភាពប្រសើរឡើង យើងមើលកន្លងមកនៅពេលដែលខាងអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ ឬក៏មជ្ឈដ្ឋានខាងក្រៅគាត់ចេញរបាយការណ៍ យើងតែងតែឃើញមានការច្រានចោល ឬប្រតិកម្មពីតំណាងរដ្ឋាភិបាលអីជាដើម។

សម្រាប់ខ្ញុំចំពោះរដ្ឋាភិបាលខ្ញុំយល់ថា គួរតែយកករណីទាំងអស់ហ្នឹង យកការរកឃើញរបស់អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិទាំងអស់ហ្នឹងយកមកពិនិត្យ និងពិចារណាមើលថា តើយើងនៅខ្វះខាតត្រង់ណា តើកន្លែងណាដែលយើងអាចរួមគ្នាធ្វើបានដើម្បីធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជារបស់យើងហ្នឹងឱ្យមានភាពប្រសើរឡើង។

អ៊ីចឹងទី១ រដ្ឋាភិបាលគួរតែបើកចំហរ ឬក៏ទទួលយកចំពោះមតិរិះគន់ មិនមែនថាគេរិះគន់ហ្នឹងសុទ្ធតែត្រូវទាំងអស់ទេ ប៉ុន្តែយើងមើលថាកន្លែងណាដែលយើងគួរទទួលបាន និងកន្លែងណាដែលយើងមិនគួរទទួល។ ឧទាហរណ៍ដូចជា កន្លងមកយើងឃើញមានយន្តការទាក់ទងជាមួយនឹងUPR ការត្រួតពិនិត្យតាមពេលវេលាកំណត់ជាយន្តការមួយរបស់អង្គការសហប្រជាជាតិ ហើយមានប្រទេសជាច្រើនដែលគាត់បានផ្តល់ជាអនុសាសន៍សម្រាប់ប្រទេសកម្ពុជាយកទៅពិនិត្យមើលក្នុងការអនុវត្ត ឬក៏ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់យើងហ្នឹង។

មួយទៀតរដ្ឋាភិបាលគួរតែប្រកាន់ខ្ជាប់ ធ្វើម៉េចគោរពនូវ កាតព្វកិច្ចរបស់ខ្លួន គឺគោរព ការពារ និងបំពេញ។ មួយទៀតយើងដឹងហើយថា ប្រទេសកម្ពុជាគឺជាប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ហើយរដ្ឋធម្មនុញ្ញក៏បានទទួលស្គាល់នូវកាតព្វកិច្ចសិទ្ធិមនុស្សដែរ ដូចមានចែងនៅក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញគឺ រដ្ឋធម្មនុញ្ញទទួលយកលិខិតបទដ្ឋានគតិយុទ្ធអន្តរជាតិនានា។

ចំពោះភាគីពាក់ព័ន្ធ ចំពោះដៃគូអភិវឌ្ឍ ធ្វើម៉េចចូលរួមជំរុញ ចូលរួមឱ្យមានការគោរពសិទ្ធិមនុស្សទាំងអស់គ្នានៅក្នុងប្រទេសកម្ពុជាឱ្យបានពេញលេញ។

Q: ចំាអរគុណ លោក រស់ សារ៉ាត់ សម្រាប់ការចំណាយពេលវេលាផ្តល់បទសម្ភាសន៍។

A: បាទ អរគុណ!៕